**សេចក្តីប្រកាសព័ត៌មាន**

**ធនាគារពិភពលោក**
**ប្រចាំកម្ពុជា**

**ស្ថានទូតអូស្ត្រាលី**
**ភ្នំពេញ**

**ទំនាក់ទំនង: ធនាគារពិភពលោក លោក ប៊ូ សារឿន** (855) 12-217-301; sbou@worldbank.org
**ស្ថានទូតអូស្ត្រាលី លោក** Lachlan Pontifex (855) 12-900-911; lachlan.pontifex@ausaid.gov.au

---

# ប្រជាជនក្រីក្រកម្ពុជា នឹងទទួលបានការគាំទ្រពីកម្មវិធីថ្មីស្តីពីសន្តិសុខស្បៀង និងសុវត្ថិភាពសង្គម

**ភ្នំពេញ ថ្ងៃទី ៤ ខែ សីហា ឆ្នាំ ២០០៩** - ថ្ងៃនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារពិភពលោក ចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយដែលមានទឹកប្រាក់ ១៣ លានដុល្លាអាមេរិក សំរាប់គាំទ្រដល់ប្រជាជនកម្ពុជាក្រីក្របំផុត និងអ្នកដែលងាយរងគ្រោះ តាមរយៈការពង្រឹងសន្តិសុខស្បៀង និងសំណាញ់សុវត្ថិភាពសង្គម ។

ធនាគារពិភពលោកបានអនុម័តកម្មវិធីប្រតិបត្តិការគោលនយោបាយអភិវឌ្ឍន៍កសិកម្មខ្នាតតូច និងការគាំពារសង្គម ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការសម្រាលដល់ផលប៉ះពាល់ដែលបង្កឡើងដោយវិបត្តិតម្លៃស្បៀងអាហារ និង វិបត្តិសេដ្ឋកិច្ចសកលលោក ។ កម្មវិធីនេះ មានគោលដៅបង្កើនសន្តិសុខស្បៀងសំរាប់គ្រួសារក្រីក្រ និងការពង្រីកការគាំពារបណ្តាញសុវត្ថិភាពសង្គម។

លោកស្រី អាណែត ឌីកសុន នាយិកាធនាគារពិភពលោកសំរាប់កម្ពុជា មានប្រសាសន៍ថា *"បើទោះបីជាប្រទេសកម្ពុជាជាប្រទេសនាំស្រូវចេញក៏ដោយ ប្រជាជនក្រីក្រងាយនឹងទទួលរងគ្រោះខ្លាំងពីការកើនឡើងតម្លៃស្បៀងអាហារ ហើយវាក៏មិនមានអ្វីមួយច្បាស់លាស់ថា កសិករដែលធ្វើកសិកម្មខ្នាតតូច មានការគាំទ្រជាចាំបាច់សំរាប់ពួកគេ ក្នុងការទាញយកឱកាស នាពេលដែលស្បៀងអាហារឡើងថ្លៃនេះ ដើម្បីផលិតឱ្យបានច្រើន"*។ លោកស្រីបន្តថា *"យើងសង្ឃឹមថាប្រតិបត្តិការនេះនឹងជួយពង្រឹងបន្ថែមចំពោះកម្មវិធីដ៏ប្រសើរដែលរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និង ដៃគូអភិវឌ្ឍន៍កំពុងតែគាំទ្រដល់វិស័យកសិកម្ម និងការគាំពារសង្គមនៅកម្ពុជា ។ កម្មវិធីនេះ ក៏អាចជួយប្រជាជនក្រីក្រ*

*ដើម្បីលើកកំពស់ផលិតភាពកសិកម្ម និងទីផ្សារ ហើយវាក៏ជួយគាំពារអ្នកដែលងាយរងគ្រោះបំផុតតាមរយៈគោលនយោបាយដ៏ប្រសើរ"។*

ជាពិសេស កម្មវិធីនេះបង្កើតឡើង ដើម្បីធានាឱ្យមានការគ្រប់គ្រងត្រួតពិនិត្យ និងបទដ្ឋានកាន់តែប្រសើរឡើងក្នុងការត្រួតពិនិត្យសម្ភារៈកសិកម្ម ដូចជា ជី និងគ្រប់ពូជ ដើម្បីបង្កើនផលិតភាពស្បៀងអាហារ នៅថ្នាក់កសិដ្ឋានខ្នាតតូច។ កម្មវិធី ក៏នឹងបង្កើនផងដែរ នូវការចុះបញ្ជីក្រុមសមាគមន៍កសិករ ដើម្បីធ្វើឱ្យកសិករម្នាក់ៗ អាចមាន លទ្ធភាពទទួលបានឥណទានកាន់តែប្រសើរ និងឱកាសរកទីផ្សារសម្រាប់ផលដំណាំរបស់ពួកគាត់។ ទន្ទឹមនឹងនេះដែរ កម្មវិធីនឹងលើកកំពស់ប្រព័ន្ធកំណត់គោលដៅសម្រាប់សុវត្ថិភាពសង្គម ដល់ប្រជាជនកម្ពុជាដែលត្រូវការបំផុត ។

មូលនិធិសរុបចំនួន ១៣ លានដុល្លាអាមេរិក សម្រាប់ប្រតិបត្តិការគោលនយោបាយអភិវឌ្ឍន៍នេះ ទទួលបានជាទឹកប្រាក់ហិរញ្ញប្បទានឥតសំណងចំនួន ៨លានដុល្លាអាមេរិក ពីកម្មវិធីទប់ស្កាត់វិបត្តិស្បៀងអាហារសកលលោក ដែលហៅកាត់ថា (GFRP) និង ហិរញ្ញប្បទានឥណទានចំនួន ៥ លានដុល្លាអាមេរិក ពីសមាគមន៍អភិវឌ្ឍន៍អន្តរជាតិ ដែលជាផ្នែកមួយរបស់ធនាគារពិភពលោក សំរាប់ប្រទេសដែលមានប្រាក់ចំណូលទាប។ កម្មវិធីទប់ស្កាត់វិបត្តិស្បៀងអាហារសកលលោក គឺគ្រប់គ្រងដោយធនាគារពិភពលោក ហើយផ្តល់ការគាំទ្រជាហិរញ្ញវត្ថុ និងជាបច្ចេកទេស ដល់ប្រទេសដែលទទួលរងផលប៉ះពាល់ដោយវិបត្តិស្បៀងអាហារសកលលោកនេះ ។

រដ្ឋាភិបាលអូស្ត្រាលី តាមរយៈទីភ្នាក់ងារអភិវឌ្ឍន៍អូស្ត្រាលី បានចូលរួមផ្តល់មូលនិធិចំនួន ២,៨ លានដុល្លាអូស្ត្រាលី សម្រាប់គាំទ្រដល់ការវិភាគនិងការកសាងសមត្ថភាព និងការរៀបចំ ព្រមទាំងការវាយតម្លៃលើសកម្មភាពសាកល្បង ដើម្បីគាំទ្រកម្មវិធីនេះ។ លោកស្រី ម៉ាហ្គ្រេត អាដាមសុន ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំកម្ពុជាមានប្រសាសន៍ថា *"យើងមានការរីករាយណាស់ចំពោះការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល ក្នុងការលើកកំពស់សេវាកម្មដល់កសិករ មានដូចជា ការបង្កើនបរិមាណពូជ និងជីដែលមានគុណភាពដល់កសិករ ពង្រឹងក្រុមកសិករ ហើយធានាថាធនធានសម្រាប់សំណាញ់សុវត្ថិភាពសង្គមដែលមានកំរិត ត្រូវបានកំណត់សំរាប់ប្រជាជនក្រីក្របំផុតក្នុងចំណោមប្រជាជនក្រីក្រនៅកម្ពុជា"។*